វ៉ុល៥, លេខ០៤, ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣

# តួនាទីរបស់យុវជនក្នុងកិច្ចការការបរទេស

ទាន សំណាង* និង រស់ សយម្ភូ**

កម្ពុជាបានចាកចេញពីរបបប្រល័យពូជសាសន៍ និងបានវិលត្រលប់មកកាន់មាគ៌ាស្តារអភិវឌ្ឍ មុខមាត់ប្រទេសជាតិឡើងវិញក្រោយឆ្នាំ១៩៧៩ ក៏ប៉ុន្តែសន្តិភាព និងវឌ្ឍនភាពពិតប្រាកដទើបកើតមាននៅឆ្នាំ១៩៩៨ ប៉ុណ្ណោះ។ ក្រោយមកបានប្រែក្លាយខ្លួនសន្សឹមៗ រហូតមានសង្គតិភាពក្នុងការអភិវឌ្ឍក្នុងរយៈពេលជាង ២ទសវត្សរ៍ចុងក្រោយនេះ។ ឆ្លងកាត់សម័យកាលជាច្រើន បើពិនិត្យលើវិស័យការបរទេសវិញ ការទទួលស្គាល់កម្ពុជាលើឆាកអន្តរជាតិ រីការងារការបរទេសរបស់កម្ពុជារដ្ឋបរទេសមួយចំនួនអាចនឹងពុំបានកត់សម្គាល់ ឬអាចមើលរំលងពីតម្លៃ និងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ភាពបុរេសកម្មការតស៊ូរបស់កម្ពុជា ដើម្បីងើបឈរនិងលើកកម្ពស់កិត្តិនាមខ្លួនឡើងវិញ។ សាកស្រមៃបន្តិចទៅមើលថា តើប្រជាជនដែលឆ្លងកាត់សម័យប្រល័យពូជសាសន៍ សង្គ្រាមស៊ីវិល ត្រូវរងការលំបាកវេទនាយ៉ាងណាខ្លះទើបមានថ្ងៃនេះ? ការប្រឹងបន្តជីវិតក្នុងសម័យប្រល័យពូជសាសន៍ ទុក្ខសោកបាត់បង់សមាជិកគ្រួសារ ទុក្ខលំបាកវង្វេងសមាជិកគ្រួសារ បាត់បង់ភាពកក់ក្តៅមិនមែនជារឿងសាមញ្ញ ហើយរឹតតែមិនមែនអាចបំភ្លេចបានងាយៗនោះទេ។ លើសពីនេះទៀត តើការដឹកនាំប្រទេសមួយដើម្បីអោយមានសន្តិភាព និងការអភិវឌ្ឍរហូតមកដល់ពេលនេះត្រូវការការតាំងចិត្ត ការលះបង់ និងការព្យាយាមបែបណាខ្លះ? តើមានភាពលំបាកបែបណា នៅពេលរដ្ឋបរទេសបន្ថែមសម្ពាធ ឬបញ្ហា? ហើយត្រូវប្រឹងងើបឈរដោយខ្លួនឯងដោយរបៀបណា? នៅពេលនេះបើនិយាយថា កម្ពុជាមានការអភិវឌ្ឍឃ្លានេះគឺងាយស្រួលនឹងនឹកដល់ និងនិយាយ តែបើពិនិត្យជាពេលវេលា និងការលះបង់តាមរយៈបុគ្គលនីមួយៗ គ្រួសារនីមួយៗ ជាកោសិការបស់សង្គមជាតិ ក៏ដូចជារបស់ជាតិជារួម វាប្រហែលជាមិនសាមញ្ញពេកទេ។ កម្ពុជា ពីអតីតកាលជាប្រទេសក្រីក្រ ខ្វះស្បៀងសម្រាប់ប្រជាជនខ្លួន តែកម្ពុជានាពេលនេះ បានក្លាយជារដ្ឋដែលមានស្បៀងពេញលេញហើយអាចចែកស្បៀងខ្លួនតាមលទ្ធភាពទៅកាន់រដ្ឋជាមិត្ត ចំណុចវិជ្ជមាននេះ គឺមានសារៈសំខាន់ណាស់ និងជាជ្រុងមួយនៃការងារការបរទេស។ កម្ពុជាបានឆ្លងកាត់សោកនាដកម្មដ៏អាក្រក់ តែកម្ពុជានៅតែមិនបានប្រែក្លាយជាចិត្តអាក្រក់ទេ។ ផ្ទុយទៅវិញ ការណ៍នេះបានក្លាយជាកម្លាំងចិត្តជំរុញអោយមានការអភិវឌ្ឍ និងលើកកម្ពស់មុខមាត់បន្ថែមទៀត ដែលទាំងនេះ យុវជនជាអ្នកបន្តវេនគួរត្រូវយកចិត្តទុកដាក់ និងបន្តមាគ៌ាដ៏ត្រឹមត្រូវនេះ។

## ការងារការបរទេស និងយុវជន

ជាទូទៅយុវជន គឺមានការផ្សារភ្ជាប់ខ្លួនជិតស្និទ្ធ ជាមួយនឹងបរិស្ថានថ្មីៗ ឬទំនើបកម្មថ្មីៗនៅក្នុងសង្គម ហើយក៏ជាក្រុមមានភាពសកម្មក្នុងការលើកកម្ពស់វប្បធម៌ខ្លួន។ ត្រង់ស្មារតីលើកតម្កើនវប្បធម៌នេះ យុវជន បាននិងកំពុងចូលរួមក្នុងការងារការបរទេស ពោលគឺភាពលេចធ្លោនៃសកម្មភាពវប្បធម៌ បច្ចេកវិទ្យា ឬសិល្បៈ ជាដើម អាចនឹងមានឥទ្ធិពល ឬទទួលបានការគាំទ្រពីប្រទេសដទៃ ដែលនឹងជួយផ្សព្វផ្សាយពីរូបភាព

*ឯកឧត្តម ទាន សំណាង** គឺជាអគ្គនាយកនៃក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

* ***លោក រស់ សយម្ភូ** គឺជានិស្សិតថ្នាក់បណ្ឌិតច្បាប់អន្តរជាតិ នៃសាកលវិទ្យាល័យ Aberdeen ចក្រភពអង់គ្លេស។

*© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

វិជ្ជមានរបស់ប្រទេសខ្លួនទៅអន្តរជាតិ ទាំងនេះបង្ហាញពីភាពខ្លាំង និងកិត្យានុភាពរបស់ប្រទេសខ្លួន តាមរយៈការផ្ទេរទស្សនៈថ្មី ការយល់ដឹងថ្មី ដល់ទស្សនិកជនបរទេស ដែលជាផ្នែកមួយសំខាន់ក្នុងការងារការបរទេស និងយុវជន។[1]

ស្របតាមទស្សនៈខាងលើ ការកែប្រែមុខមាត់ ក៏ដូចជាការចាប់អារម្មណ៍លើដំណើរការអភិវឌ្ឍន៍របស់កម្ពុជា គួរមានការយកចិត្តទុកដាក់ពីយុវជន ពិសេសក្នុងយុគសម័យសាកល-ភាវូបនីយកម្ម និងបដិវត្តន៍ឧស្សាហកម្មទី៤ នេះ ដែលការផ្សារភ្ជាប់ប្រទេសនានាក្នុងសហគមន៍អន្តរជាតិមានភាពស្អិតរមួត។ ការណ៍នេះ ជាកាលានុវត្តភាពយ៉ាងសំខាន់សម្រាប់ការលើកកម្ពស់ និងផ្សព្វផ្សាយពីរូបភាពវិជ្ជមានរបស់កម្ពុជា។ ជាការពិតណាស់ កម្ពុជាបានហែលឆ្លងបរិបទនយោបាយជាច្រើនដំណាក់កាល ដូច្នេះបទពិសោធន៍ការងារការបរទេសកម្ពុជាមិនមែនសាមញ្ញ ហើយក៏មិនតិចនោះទេ។ ជាការកត់សម្គាល់របស់អ្នកនិពន្ធផ្ទាល់ រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និងអំឡុងឆ្នាំ២០២៣ ពិភពលោកបាននិងកំពុងជួបបញ្ហាជាច្រើនដូចជា វិបត្តិជំងឺកូវីដ១៩ សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន វិបត្តិស្បៀងពិភពលោក ជាដើម ក៏ប៉ុន្តែ កម្ពុជាបានពុះពារ និងសម្រេចបានដោយជោគជ័យ និងយ៉ាងត្រចះត្រចង់ក្នុងការដឹកនាំកិច្ចប្រជុំកម្រិតតំបន់ និងអន្តរជាតិ ជាមួយលទ្ធផលផ្លែផ្កាគួរជាទីមោទនៈ។ គួរបញ្ជាក់ផងដែរថា កម្ពុជាបានទទួលអម្រែកជាប្រធានប្តូរវេនដឹកនាំកិច្ចប្រជុំអាស៊ី-អ៊ឺរ៉ុប(ASEM) នៅក្នុងឆ្នាំ២០២១ ហើយក្នុងឆ្នាំ២០២២ កម្ពុជាជាប្រធានប្តូរវេនអាស៊ានដែលទទួលរៀបចំកិច្ចប្រជុំជាច្រើន ប៉ុន្តែក្នុងនោះមានកិច្ចប្រជុំធំៗពីរគឺ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន កាលពីដើមខែសីហា ឆ្នាំ២០២២ និងកិច្ចប្រជុំកំពូលអាស៊ាន នៅសប្តាហ៍ទី២ ខែវិច្ឆិកា ឆ្នាំ២០២២។ ជាមួយគ្នានេះ កម្ពុជា បានរៀបចំជាម្ចាស់ផ្ទះលើកដំបូងនូវការប្រកួតស៊ីហ្គេម (SEA Games) យ៉ាងជោគជ័យត្រចះត្រចង់ កាលពីខែឧសភាកន្លងទៅ ក៏ដូចជា អាស៊ានប៉ារ៉ាហ្គេម (ASEAN Para Games) កាលពីដើមខែមិថុនាកន្លងទៅ ដោយមានការកោតសរសើរអំពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ។ សំណួរថា តើកិច្ចប្រជុំ និងព្រឹត្តិការណ៍ខាងលើ មានទាក់ទងអ្វីនឹងកិច្ចការការបរទេស? ទាក់ទងអ្វីនឹងយុវជន? ការរៀបចំកិច្ចប្រជុំ ASEM និង អាស៊ានជារួមគឺជាការផ្តោតទៅលើការពិភាក្សាស្វែងរកដំណោះស្រាយ ក៏ដូចជាពិនិត្យលើកាលានុវត្តភាពក្នុងការសហការគ្នា នៅក្នុងសហគមន៍អន្តរជាតិ ក្នុងតំបន់ រវាងរដ្ឋ និងរដ្ឋ ក៏ដូចជារដ្ឋនិងស្ថាប័នពាក់ព័ន្ធក្នុងបញ្ហាតំបន់ រឺសាកលលោក។ ដោយឡែកព្រឹត្តិការណ៍ស៊ីហ្គេម និង អាស៊ានប៉ារ៉ាហ្គេម គឺជាការប្រកួតកីឡាក្នុងតំបន់ ក៏ប៉ុន្តែបានឆ្លុះបញ្ចាំងអំពីកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ ក្នុងវិស័យកីឡា។ អ្វីដែលអត្ថបទនេះចង់បង្ហាញគឺយុវជន និងការងារការបរទេស ដែលត្រង់ចំណុចនេះ សូមគូសបញ្ជាក់ថា ព្រឹត្តិការណ៍និងកិច្ចប្រជុំខាងលើបានជំរុញទំនាក់ទំនង រវាងបុគ្គលនិងបុគ្គល យុវជននិងយុវជន (People / Public Diplomacy) មិនមែនតែក្នុងកិច្ចពិធីផ្លូវការនោះទេ។ ទំនាក់ទំនងនេះជាកត្តាមួយយ៉ាងសំខាន់ ក្នុងការពង្រីកនិងពង្រឹងសន្តិភាព ការយល់ពីគ្នាទៅវិញទៅមក ពិសេសការផ្សព្វ-ផ្សាយនូវរូបភាពវិជ្ជមាន ដែលមានជាអាទិ៍សកម្មភាពវប្បធម៌ បច្ចេកវិទ្យា ឬសិល្បៈរបស់កម្ពុជា ជាមួយប្រទេសជាមិត្ត។ និយាយមួយបែប ការប្រាស្រ័យទាក់ទងគ្នាជាអន្តរប្រទេស អាចនឹងជំរុញការផ្លាស់ប្តូរបទពិសោធន៍ ការយល់ឃើញ ក៏ដូចជាវប្បធម៌ ដែលអាចនាំអោយមានការខិតជិតគ្នារវាងស្ថាប័ននានា ក៏ដូចជារដ្ឋ។ ក្នុងនោះយុវជន ក៏បានដើរតួយ៉ាងសំខាន់ ហើយពេលខ្លះក្លាយជាអ្នកតំណាងជាតិខ្លួនផងដែរ ព្រោះថាទំនាក់ទំនងរវាងបុគ្គលនិងបុគ្គល មិនមែនបង្ហាញអំពីតែអត្ត-សញ្ញាណខ្លួននោះទេ តែក៏មានទំនាក់ទំនង និងផលជះដល់ជាតិផងដែរ។

[1] Modaber, R. (2016). Role of Youth Diplomacy in Governments′ Foreign Relationships by Using YNGOs Capacity (Youth Non-governmental Organizations). *Journal of Politics and Law, 9*(2), 219. https://doi.org/10.5539/jpl.v9n2p219

## យុវជន និងឧត្តមភាពកម្ពុជា

នៅពេលដែលនឹកឃើញដល់ ASEM, អាស៊ាន, ស៊ីហ្គេម និង អាស៊ានប៉ារ៉ាហ្គេម ប្រហែលជាបុគ្គលមួយចំនួនអាចយល់បានថា ជាការងាររបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រឺ របស់គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍។ ការយល់ឃើញបែបនេះគឺមិនខុសទេ ព្រោះស្ថាប័នទាំងពីរខាងលើជាសេនាធិការរបស់រដ្ឋាភិបាល ក្នុងការរៀបចំកិច្ចការនានាពាក់ព័ន្ធខាងលើ។ បើយោងតាមយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ២០១៩-២០២៣ ទំព័រទី៨ ក៏បានបង្ហាញអំពីការងារជំរុញការផ្លាស់ប្តូរវប្បធម៌ និងកីឡា ដែលជាផ្នែកមួយដែល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិទទួលបានការយកចិត្តទុកដាក់ ដើម្បីពង្រឹងនិងការពារផលប្រយោជន៍ជាតិកម្ពុជា។ អត្ថបទនេះមិនមានបំណងបង្ហាញអ្វីជាគោលនយោបាយការបរទេសកម្ពុជានោះទេ តែមានបំណងបង្ហាញថា ការទទួលបានជោគជ័យ និងការសាទរដល់កម្ពុជាក្នុងនាមជាប្រធានប្តូរវេន ASEM, អាស៊ាន និងជាម្ចាស់ផ្ទះស៊ីហ្គេម និង អាស៊ានប៉ារ៉ាហ្គេម នោះ គឺបានបង្ហាញថា (១) កម្ពុជាមានធនធានមនុស្សប្រកបដោយសមត្ថភាពគ្រប់គ្រាន់ និង (២) យុវជនបាននិងកំពុងចូលរួមលើកកម្ពស់មុខមាត់ប្រទេស។ គួររំលឹកផងដែរថា ចំណុចទាំងពីរខាងលើ គឺមានភាពប្រទាក់ក្រឡាគ្នា មានន័យថា ស្ថាប័នជាសេនាធិការត្រូវមានជំហរនិងសមត្ថភាពពិតប្រាកដ និងមានការគាំទ្រគ្រប់គ្រាន់ រាប់បញ្ចូលទាំង ខ្លឹមសារ សម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ជាដើម។ អ្នកនិពន្ធ ក៏បានកត់សម្គាល់ផងដែរថា យុវជនកម្ពុជាបានចូលរួមទទួលភារកិច្ច និងការទទួលខុសត្រូវទាំងខ្លឹមសារ ទាំងការរៀបចំសម្របសម្រួលកម្មវិធី (អត្ថបទនេះមិនបានរៀបរាប់ការចូលរួមរបស់យុវជនអស់នោះទេ) ជាច្រើនផងដែរ ឧទាហរណ៍ ការដឹកនាំ និងការចូលរួមរបស់យុវជនកម្ពុជា ក្នុងកិច្ចប្រជុំកំពូលអ្នកដឹកនាំវ័យក្មេងនៃមូលនិធិអាស៊ី-អឺរ៉ុបលើកទី៤ (4th ASEF Young Leaders Summit) ជាវេទិកាអមមួយរបស់កិច្ចប្រជុំ ASEM, ការចូលរួមជាមន្ត្រីទំនាក់ទំនង (Liaison Officer) សម្រាប់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងកិច្ចប្រជុំកំពូលអាស៊ាន, និងការចូលរួមរបស់យុវជនក្នុងនាមជាអត្តពលិក រឺ យុវជនស្ម័គ្រចិត្ត សម្រាប់ព្រឹត្តិការណ៍ស៊ីហ្គេម និង អាស៊ានប៉ារ៉ាហ្គេម ដែលកម្មវិធី និងព្រឹត្តិការណ៍ខាងលើទាមទារឱ្យមានការទទួលខុសត្រូវខ្ពស់។ លើសពីនេះ ក៏មានសកម្មភាពផ្សេងទៀតដែលប្រជាជន និងយុវជនបានចូលរួមផ្សព្វផ្សាយរូបភាពវិជ្ជមានរបស់កម្ពុជា ដែលមានដូចជា ការថែរក្សាអនាម័យ និងសោភ័ណភាពទីក្រុង ការយោគយល់ចំពោះបញ្ហាចរាចរណ៍និងការបិទផ្លូវ ការចូលរួមយល់ដឹងនិងចែកចាយព័ត៌មានអំពីកិច្ចប្រជុំពាក់ព័ន្ធនានា ក៏ដូចជាសមិទ្ធផលដែលទទួលបានជាវិជ្ជមានជាដើម សុទ្ធតែបានរួមចំណែកលើកមុខមាត់ និងឧត្តមភាពកម្ពុជា។ ការរៀបរាប់ខាងលើមានចំណុចរួមមួយគឺ យុវជនជាកម្លាំងសំខាន់មួយដើម្បីទទួលបានភាពជោគជ័យ និងលទ្ធផលជាទីគាប់ប្រសើរទាំងនេះ ហើយយុវជនបានទទួលការងារ ដែលមានការទទួលខុសត្រូវខ្ពស់ បានចូលរួមបង្ហាញសមត្ថភាពខ្លួន និងបានផ្សព្វផ្សាយទៅកាន់បរទេសថា យុវជនខ្មែរធ្វើបាន។ ដូចបានរៀបរាប់សកម្មភាពខាងលើ អ្នកអានអាចប្រហែលយល់បានថា ការសម្រេចបានសមិទ្ធផលទាំងនេះគឺបានសបញ្ជាក់ថា យុវជនខ្មែរបាននិងកំពុង «ជឿថាខ្មែរធ្វើបាន» ហើយតាមរយៈកិច្ចខិតខំប្រឹងប្រែង និងចូលរួមរបស់យុវជនខ្មែរម្នាក់ៗជាមួយចំណែក បាននាំឱ្យកម្ពុជារីកមុខរីកមាត់ ទទួលបានការកោតសរសើរ និងបានលើកកម្ពស់កិត្តិនាមកម្ពុជានៅក្នុងតំបន់ និងពិភពលោក។ ភាពសាមគ្គី និងប្រឹងប្រែងនៃយុវជនកម្ពុជា តាមរយៈព្រឹត្តិការណ៍ និងកម្មវិធីខាងលើ បានចូលរួមចំណែកបង្ហាញជាសារមួយថា «យើងជឿជាក់លើកម្ពុជា» និង «កម្ពុជា ប្រទេសតូចតែមានបេះដូងធំ»។

ជារួម ការរៀបចំ និងសម្រេចបានដោយជោគជ័យនៃកិច្ចប្រជុំ រឺព្រឹត្តិការណ៍កម្រិតតំបន់ក្តី អន្តរជាតិក្តី គឺតែងមានការចូលរួមសហប្រតិបត្តិការយ៉ាងស្អិតរមួតរវាងស្ថាប័ន និងក្រុមផ្សេងៗគ្នា ពិសេសការចូលរួមរបស់យុវជន ដោយគោរពតាមភារកិច្ច និងកាតព្វកិច្ចដែលខ្លួនតាមរយៈការផ្តល់សេចក្តីទុកចិត្តរបស់ថ្នាក់ដឹកនាំ និងអោយតម្លៃគ្នាទៅវិញទៅមក។ ស្តែងតាមបទ

ពិសោធន៍កម្មវិធីរៀបរាប់នានាខាងលើ ការចូលរួមរបស់ «យុវជនក្នុងកិច្ចការការបរទេស» គឺជាផ្នែកមួយរួមចំណែកដល់ភាពជោគជ័យនៃព្រឹត្តិការណ៍សំខាន់ៗកន្លងមក រួមមានការចូលរួមផ្សព្វផ្សាយ និងលើកកម្ពស់កិត្យានុភាព និងកិត្តិនាមកម្ពុជាឱ្យកាន់តែល្បីរន្ទឺ។ កម្ពុជាធ្លាប់ជាប្រទេសដែលធ្លាក់ដល់ចំណុចសូន្យ តែកម្ពុជាប្រឹងងើបឈរ ហើយបាននិងកំពុងទទួលបាននូវផ្លែផ្កាបែបនេះ គឺកម្ពុជាអាចធ្វើបាន។ ពេលកម្ពុជា ៤៤ឆ្នាំមុនមានភាពខ្ទេចខាត ស្ទើរតែគ្មានអ្វីទាំងអស់ តែដំណើរវិវត្តន៍កម្ពុជា ក្នុងឆ្នាំ២០២៣ កំពុងមានវឌ្ឍនភាពយ៉ាងប្រសើរ ហើយកាន់តែសំខាន់នោះគឺ ការចូលរួមរបស់យុវជនក្នុងការងារសំខាន់ៗខាងលើបានបង្ហាញថា កម្ពុជាមានយុវជនពោរពេញដោយសមត្ថភាព ជាមួយឆន្ទៈឥតងាករេដើម្បីបុព្វហេតុជាតិមាតុភូមិ។ ទោះជាយ៉ាងនេះក្តីដំណើរការអភិវឌ្ឍន៍ប្រទេសពុំទាន់បិទបញ្ចប់នាពេលនេះទេ ដោយគោលដៅកម្ពុជាឆ្នាំ២០៣០ និងកម្ពុជាឆ្នាំ២០៥០ កំពុងតែទន្ទឹងរង់ចាំ ពិសេសត្រូវការការចូលរួម និងបន្តរក្សាសង្គតិភាពនៃស្មារតីទទួលខុសត្រូវដើម្បីជាតិ និងមាតុភូមិពីយុវជនខ្មែរក្នុងការបន្តការការពារដំណើរអភិវឌ្ឍន៍ រក្សាសន្តិភាពឱ្យបានគង់វង្សតទៅមុខទៀត។

អត្ថបទនេះសូមបញ្ចប់ដោយលើកយកឃ្លាមួយពីសិលាចារិកខ្មែរ «បើផលដែលកើតចេញពីបុណ្យរបស់ខ្ញុំមានមែន [ជាតិក្រោយៗ] សូមឱ្យខ្ញុំឆាប់មកកើតនៅកម្ពុជា [ទៀត] »។[2]

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
The Kampus Building, Unit 1D, Street 93, Sangkat Tonle Bassac, Khan Chamkarmon
info@cd-center.org | (+855) 10 950 456 www.cd-center.org

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

[2] អាំង ជូលាន «សូមកើតមកជាខ្មែរទៀត» https://www.yosothor.org/publications/khmer-renaissance/chapter-four/som-kert-mok-jea-khmer-teat.html